# តារាងឧបសម្ព័ន្ធ

## ស្តីពីការគ្រប់គ្រងការប្រមូលចំណូលពីសេវាផ្សេងៗក្នុងតំបន់រមណីយដ្ឋានអង្គរ

### I-ការរៀបចំពិធីទទួលទានអាហារ និងសម្តែងសិល្បៈ ក្នុងឧទ្យានអង្គរ និងតំបន់ក្រោមសមត្ថកិច្ចរបស់អាជ្ញាធរអប្សរា

| ល.រ | បរិយាយ | | | | ថ្លៃសេវា (ដុល្លារ) | រយៈពេលដាក់ពាក្យផ្តល់សេវា(ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|---|---|
| | ប្រភេទសេវា | ទីតាំង | កូដ | ចំនួនភ្ញៀវ (នាក់) | | | |
| ១ | ពិធីទទួលទានអាហារពេលល្ងាច | | | | | | |
| | | ព្រះលានជល់ដំរី | DOET01 | ≤50 | 1640 USD | ០៥ថ្ងៃ | |
| | | | DOET02 | 51-100 | បន្ថែម 30 USD ក្នុង១នាក់ | | |
| | | | DOET03 | 101-150 | បន្ថែម 35 USD ក្នុង១នាក់ | | |
| | | | DOET04 | 151-400 | បន្ថែម 40 USD ក្នុង១នាក់ | | |
| | | | DOET05 | 401-800 | បន្ថែម 45 USD ក្នុង១នាក់ | | |
| | | ប្រាសាទបី | DOB01 | ≤50 | 1540 USD | | |
| | | | DOB02 | 51-100 | បន្ថែម 28 USD ក្នុង១នាក់ | | |
| | | | DOB03 | 101-150 | បន្ថែម 33 USD ក្នុង១នាក់ | | |
| | | | DOB04 | 151-400 | បន្ថែម 38 USD ក្នុង១នាក់ | | |
| | | | DOB05 | 401-500 | បន្ថែម 43 USD ក្នុង១នាក់ | | |
| | | ប្រាសាទធម្មនន្ទ | DOTN01 | ≤50 | 1520 USD | | |
| | | | DOTN02 | 51-100 | បន្ថែម 27 USD ក្នុង១នាក់ | | |
| | | | DOTN03 | 101-150 | បន្ថែម 32 USD ក្នុង១នាក់ | | |
| | | | DOTN04 | 151-400 | បន្ថែម 37 USD ក្នុង១នាក់ | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ប្រាសាទក្រវ៉ាន់ | DOKV01 | ≤50 | **1320 USD** | | |
| | | | DOKV02 | 51-100 | បន្ថែម 24 USD ក្នុង១នាក់ | | |
| | | | DOKV03 | 101-200 | បន្ថែម 29 USD ក្នុង១នាក់ | | |
| | | ប្រាសាទបន្ទាយសំរែ ប្រាសាទវត្តអធ្វារ | DOBS01 | ≤50 | **1120 USD** | | |
| | | | DOBS02 | 51-100 | បន្ថែម 20 USD ក្នុង១នាក់ | | |
| | | | DOBS03 | 101-200 | បន្ថែម 25 USD ក្នុង១នាក់ | | |
| ២ | ពិធីសម្តែងសិល្បៈ | | | | | | |
| | | ព្រះលានជល់ដំរី | SOET01 | ≤50 | **1640 USD** | | |
| | | | SOET02 | 51-100 | បន្ថែម 30 USD ក្នុង១នាក់ | | |
| | | | SOET03 | 101-150 | បន្ថែម 35 USD ក្នុង១នាក់ | | |
| | | | SOET04 | 151-400 | បន្ថែម 40 USD ក្នុង១នាក់ | | |
| | | | SOET05 | 401-800 | បន្ថែម 45 USD ក្នុង១នាក់ | | |
| | | ប្រាសាទបី | SOB01 | ≤50 | **1540 USD** | ០៥ថ្ងៃ | |
| | | | SOB02 | 51-100 | បន្ថែម 28 USD ក្នុង១នាក់ | | |
| | | | SOB03 | 101-150 | បន្ថែម 33 USD ក្នុង១នាក់ | | |
| | | | SOB04 | 151-400 | បន្ថែម 38 USD ក្នុង១នាក់ | | |
| | | | SOB05 | 401-500 | បន្ថែម 43 USD ក្នុង១នាក់ | | |
| | | ប្រាសាទធម្មនន្ទ | SOTN01 | ≤50 | **1520 USD** | | |
| | | | SOTN02 | 51-100 | បន្ថែម 27 USD ក្នុង១នាក់ | | |
| | | | SOTN03 | 101-150 | បន្ថែម 32 USD ក្នុង១នាក់ | | |
| | | | SOTN04 | 151-400 | បន្ថែម 37 USD ក្នុង១នាក់ | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ប្រាសាទក្រវ៉ាន់ | SOKV01 | ≤50 | 1320 USD | | |
| | | | SOKV02 | 51-100 | បន្ថែម 24 USD ក្នុង១នាក់ | | |
| | | | SOKV03 | 101-200 | បន្ថែម 29 USD ក្នុង១នាក់ | | |
| | | ប្រាសាទបន្ទាយសំរែ ប្រាសាទវត្តអធ្វារ | SOBS01 | ≤50 | 1120 USD | | |
| | | | SOBS02 | 51-100 | បន្ថែម 20 USD ក្នុង១នាក់ | | |
| | | | SOBS03 | 101-200 | បន្ថែម 25 USD ក្នុង១នាក់ | | |
| ៣ | ពិធីទទួលទានអាហារពេលល្ងាច និងសម្តែងសិល្បៈ | | | | | | |
| | | ព្រះលានជល់ដំរី | DSET01 | ≤50 | 2340 USD | ០៥ថ្ងៃ | |
| | | | DSET02 | 51-100 | បន្ថែម 44 USD ក្នុង១នាក់ | | |
| | | | DSET03 | 101-150 | បន្ថែម 49 USD ក្នុង១នាក់ | | |
| | | | DSET04 | 151-400 | បន្ថែម 54 USD ក្នុង១នាក់ | | |
| | | | DSET05 | 401-800 | បន្ថែម 59 USD ក្នុង១នាក់ | | |
| | | ប្រាសាទបី | DSB01 | ≤50 | 2200 USD | | |
| | | | DSB02 | 51-100 | បន្ថែម 41 USD ក្នុង១នាក់ | | |
| | | | DSB03 | 101-150 | បន្ថែម 46 USD ក្នុង១នាក់ | | |
| | | | DSB04 | 151-400 | បន្ថែម 51 USD ក្នុង១នាក់ | | |
| | | | DSB05 | 401-500 | បន្ថែម 56 USD ក្នុង១នាក់ | | |
| | | ប្រាសាទធម្មនន្ទ | DSTN01 | ≤50 | 2160 USD | | |
| | | | DSTN02 | 51-100 | បន្ថែម 40 USD ក្នុង១នាក់ | | |
| | | | DSTN03 | 101-150 | បន្ថែម 45 USD ក្នុង១នាក់ | | |
| | | | DSTN04 | 151-400 | បន្ថែម 50 USD ក្នុង១នាក់ | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ប្រាសាទក្រវ៉ាន់ | DSKV01 | ≤50 | 1880 USD | | |
| | | | DSKV02 | 51-100 | បន្ថែម 35 USD ក្នុង១នាក់ | | |
| | | | DSKV03 | 101-200 | បន្ថែម 40 USD ក្នុង១នាក់ | | |
| | | ប្រាសាទបន្ទាយសំរែ<br>ប្រាសាទវត្តអធ្វារ | DSBS01 | ≤50 | 1590 USD | | |
| | | | DSBS02 | 51-100 | បន្ថែម 29 USD ក្នុង១នាក់ | | |
| | | | DSBS03 | 101-200 | បន្ថែម 34 USD ក្នុង១នាក់ | | |
| ៤ | ពិធី Cocktail | | | | | | |
| | | ប្រាសាទបី | CTB01 | ≤10 | 350 USD | ០៥ថ្ងៃ | |
| | | | CTB02 | 11-40 | បន្ថែម 32 USD ក្នុង១នាក់ | | |
| | | | CTB03 | 41-100 | បន្ថែម 37 USD ក្នុង១នាក់ | | |
| | | | CTB04 | 101-500 | បន្ថែម 42 USD ក្នុង១នាក់ | | |
| | | ប្រាសាទជ្រុង | CTCH01 | ≤10 | 350 USD | | |
| | | | CTCH02 | 11-50 | បន្ថែម 32 USD ក្នុង១នាក់ | | |
| | | | CTCH03 | 41-100 | បន្ថែម 37 USD ក្នុង១នាក់ | | |
| | | ប្រាសាទភ្នំក្រោម<br>ប្រាសាទវត្តអធ្វារ | CTPK01 | ≤10 | 250 USD | | |
| | | | CTPK02 | 11-40 | បន្ថែម 22 USD ក្នុង១នាក់ | | |
| | | | CTPK03 | 41-100 | បន្ថែម 27 USD ក្នុង១នាក់ | | |
| | | | CTPK04 | 101-500 | បន្ថែម 32 USD ក្នុង១នាក់ | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ប្រាសាទភ្នំបូក | CTPB01 | ≤10 | 250 USD | | |
| | | | CTPB02 | 11-40 | បន្ថែម 22 USD ក្នុង១នាក់ | | |
| | | | CTPB03 | 41-100 | បន្ថែម 27 USD ក្នុង១នាក់ | | |
| | | | CTPB04 | 101-500 | បន្ថែម 32 USD ក្នុង១នាក់ | | |
| ៥ | ពិធីទទួលទានអាហារពេលព្រឹក | | | | | | |
| | | ប្រាសាទបី | BFB01 | ≤10 | 500 USD | ០៥ថ្ងៃ | |
| | | | BFB02 | 11-40 | បន្ថែម 47 USD ក្នុង១នាក់ | | |
| | | | BFB03 | 41-100 | បន្ថែម 52 USD ក្នុង១នាក់ | | |
| | | | BFB04 | 101-500 | បន្ថែម 57 USD ក្នុង១នាក់ | | |
| | | ស្រះស្រង់ ប្រាសាទវត្តអធ្វារ | BFSS01 | ≤10 | 500 USD | | |
| | | | BFSS02 | 11-40 | បន្ថែម 47 USD ក្នុង១នាក់ | | |
| | | | BFSS03 | 41-100 | បន្ថែម 52 USD ក្នុង១នាក់ | | |
| | | | BFSS04 | 101-500 | បន្ថែម 57 USD ក្នុង១នាក់ | | |

## II-ការថតវីដេអូ និងរូបភាពសន្លឹកក្នុងឧទ្យានអង្គរ និងតំបន់ក្រោមសមត្ថកិច្ចរបស់អាជ្ញាធរអប្សរា

| ល.រ | បរិយាយ | | ថ្លៃសេវា (ដុល្លារ) / ក្នុង១ថ្ងៃ | | | | | | | | រយៈពេលដាក់ពាក្យ (ថ្ងៃធ្វើការ) |
|---|---|---|---|---|---|---|---|---|---|---|---|
| | ប្រភេទសេវា | កូដ | ជម្រើស ទី១ | | ជម្រើស ទី២ | | ជម្រើស ទី៣ | | ជម្រើស ទី៤ | | |
| | | | បរទេស | ក្នុងស្រុក | បរទេស | ក្នុងស្រុក | បរទេស | ក្នុងស្រុក | បរទេស | ក្នុងស្រុក | |
| ២.១ ការថតខ្សែភាពយន្ត កម្មវិធីទូរទស្សន៍ និងស្ប៉តពាណិជ្ជកម្ម | | | | | | | | | | | |
| ៦ | ការថតខ្សែភាពយន្តខ្នាតធំ | VSF01 | 4 500 USD | 450 USD | 3 000 USD | 300 USD | 2 000 USD | 200 USD | 1 000 USD | 100 USD | ១០ថ្ងៃ |
| ៧ | ការថតខ្សែភាពយន្តខ្នាតតូច | VSF02 | 1000 USD | 100 USD | 800 USD | 80 USD | 600 USD | 60 USD | 400 USD | 40 USD | ១០ថ្ងៃ |
| ៨ | ការថតខ្សែភាពយន្តភាគ ឬភាពយន្តទូរទស្សន៍ខ្នាតធំ | VSF03 | 1 500 USD | 150 USD | 1 200 USD | 120 USD | 1 000 USD | 100 USD | 800 USD | 80 USD | ១០ថ្ងៃ |
| ៩ | ការថតខ្សែភាពយន្តភាគ ឬភាពយន្តទូរទស្សន៍ខ្នាតតូច | VSF04 | 900 USD | 90 USD | 700 USD | 70 USD | 500 USD | 50 USD | 300 USD | 30 USD | ១០ថ្ងៃ |
| ១០ | ការថតចម្រៀងកាយវិការ | VSF05 | 1 500 USD | 150 USD | 1 200 USD | 120 USD | 1 000 USD | 100 USD | 800 USD | 80 USD | ៥ថ្ងៃ |
| ១១ | ការថតកម្មវិធីទូរទស្សន៍ជាល្បែងកម្សាន្ត ឬការប្រកួតប្រជែងខ្នាតធំ | VSF06 | 4 500 USD | 450 USD | 3 000 USD | 300 USD | 2 000 USD | 200 USD | 1 000 USD | 100 USD | ៥ថ្ងៃ |
| ១២ | ការថតកម្មវិធីទូរទស្សន៍ជាល្បែងកម្សាន្ត ឬការប្រកួតប្រជែងខ្នាតតូច | VSF07 | 1 500 USD | 150 USD | 1 200 USD | 120 USD | 1 000 USD | 100 USD | 800 USD | 80 USD | ៥ថ្ងៃ |
| ១៣ | ការថតស្ប៉តពាណិជ្ជកម្មផលិតផលបរទេសខ្នាតធំ | VSF08 | 10 000 USD | N/A | 5 000 USD | N/A | 3 000 USD | N/A | 1 500 USD | N/A | ៥ថ្ងៃ |
| ១៤ | ការថតស្ប៉តពាណិជ្ជកម្មផលិតផលបរទេសខ្នាតតូច | VSF09 | 2 500 USD | N/A | 1 250 USD | N/A | 750 USD | N/A | 350 USD | N/A | ៥ថ្ងៃ |
| ១៥ | ការថតស្ប៉តពាណិជ្ជកម្មផលិតផលជាតិ | VSF10 | N/A | 2 000 USD | N/A | 1 000 USD | N/A | 600 USD | N/A | 300 USD | ៥ថ្ងៃ |
| ១៦ | ការថតវីដេអូឯកសារផ្សេងៗ ឬកម្មវិធីទូរទស្សន៍ | VSF11 | 400 USD | 200 USD | 300 USD | 150 USD | 200 USD | 100 USD | 100 USD | 50 USD | ៥ថ្ងៃ |
| ១៧ | ព័ត៌មាន និងសារព័ត៌មាន | VSF12 | ឥតបង់ថ្លៃ | ឥតបង់ថ្លៃ | ឥតបង់ថ្លៃ | ឥតបង់ថ្លៃ | ឥតបង់ថ្លៃ | ឥតបង់ថ្លៃ | ឥតបង់ថ្លៃ | ឥតបង់ថ្លៃ | ៥ថ្ងៃ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| **២.២ ការថតរូបភាពសន្លឹក** | | | | | | | | | | | |
| ១៨ | ការថតរូបភាព ដើម្បីផ្សព្វផ្សាយពីផលិតផលបរទេសខ្នាតធំ | PHS01 | 5 000 USD | N/A | 2 500 USD | N/A | 1 500 USD | N/A | 800 USD | N/A | ៥ថ្ងៃ |
| ១៩ | ការថតរូបភាព ដើម្បីផ្សព្វផ្សាយពីផលិតផលបរទេសខ្នាតតូច | PHS02 | 1 250 USD | N/A | 650 USD | N/A | 350 USD | N/A | 200 USD | N/A | ៥ថ្ងៃ |
| ២០ | ការថតរូបភាព ដើម្បីផ្សព្វផ្សាយពីផលិតផលជាតិ | PHS03 | N/A | 1 000 USD | N/A | 500 USD | N/A | 300 USD | N/A | 100 USD | ៥ថ្ងៃ |
| ២១ | ការថតរូបភាព សម្រាប់លក់ និងផលិតវត្ថុអនុស្សាវរីយ៍ | PHS04 | 800 USD | 300 USD | 700 USD | 250 USD | 600 USD | 200 USD | 500 USD | 150 USD | ៥ថ្ងៃ |
| ២២ | ការថតរូបភាព ដើម្បីដាក់ក្នុងសៀវភៅមគ្គុទ្ទេសក៍ សៀវភៅកាតាឡុក ទស្សនាវដ្តី ឬសៀវភៅ បោះពុម្ពផ្សព្វផ្សាយលក់ | PHS05 | 600 USD | 200 USD | 500 USD | 150 USD | 400 USD | 100 USD | 300 USD | 50 USD | ៥ថ្ងៃ |
| ២៣ | ការថតរូបភាព ដើម្បីចងក្រងឯកសារស្រាវជ្រាវ រៀបចំអត្ថបទក្នុងសារព័ត៌មាន និក្ខេបបទបញ្ចប់ការសិក្សា ឬការបោះពុម្ពផ្សព្វផ្សាយលើកស្ទួយពីវិស័យទេសចរណ៍នៅកម្ពុជា មិនមែនជាអាជីវកម្ម | PHS06 | ឥតបង់ថ្លៃ | ឥតបង់ថ្លៃ | ឥតបង់ថ្លៃ | ឥតបង់ថ្លៃ | ឥតបង់ថ្លៃ | ឥតបង់ថ្លៃ | ឥតបង់ថ្លៃ | ឥតបង់ថ្លៃ | ៥ថ្ងៃ |
| ២៤ | ការថតរូបភាពក្នុងឈុតអាពាហ៍ពិពាហ៍ ដែលមិនប៉ះពាល់គុណតម្លៃអង្គរ ដើម្បីចងក្រងទុកជាអនុស្សាវរីយ៍ | PHS07 | 200 USD | ឥតបង់ថ្លៃ | 200 USD | ឥតបង់ថ្លៃ | 200 USD | ឥតបង់ថ្លៃ | 200 USD | ឥតបង់ថ្លៃ | ៥ថ្ងៃ |

**សំគាល់៖**

ជម្រើសទី១ - ប្រាសាទអង្គរវត្ត និងប្រាសាទផ្សេងទៀត

ជម្រើសទី២ - ប្រាសាទបាយ័ន តាព្រហ្ម បន្ទាយស្រី និងប្រាសាទផ្សេងទៀត លើកលែងប្រាសាទអង្គរវត្ត

ជម្រើសទី៣ - ប្រាសាទបាគង ព្រះគោ ភ្នំបាខែង មេបុណ្យខាងកើត ប្រែរូប តាកែវ បន្ទាយក្តី ខ្លោងទ្វារអង្គរធំ វិមានអាកាស បាពួន ព្រះលានជល់ដំរី ព្រះលានស្តេចគម្លង់ ព្រះខ័ន នាគព័ន្ធ ប្រាសាទមេបុណ្យខាងលិច បារាយណ៍ទឹកថ្លា និងប្រាសាទបេងមាលា លើកលែងប្រាសាទអង្គរវត្ត បាយ័ន តាព្រហ្ម និងបន្ទាយស្រី

ជម្រើសទី៤ - ប្រាសាទដទៃទៀត ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរអប្សរា ក្រៅពីជម្រើសទី១ ២ ៣

## III-ការស្នើសុំការអនុញ្ញាតផ្សេងៗ ក្នុងឧទ្យានអង្គរ និងតំបន់ក្រោមសមត្ថកិច្ចរបស់អាជ្ញាធរអប្សរា

| ល.រ | បរិយាយ | | ថ្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | ប្រភេទសេវា | កូដ | | | |
| ៣.១ | **ការស្នើសុំចេញ-ចូលរមណីយដ្ឋានអង្គរ និងតំបន់ក្រោមសមត្ថកិច្ចរបស់អាជ្ញាធរអប្សរា** | | | | |
| ២៥ | ការចូលទស្សនារមណីយដ្ឋានអង្គរសម្រាប់គណៈប្រតិភូផ្លូវការជូ | FOC01 | *ឥតបង់ថ្លៃ* | *៣ថ្ងៃ* | |
| ២៦ | ការចូលក្នុងរមណីយដ្ឋានអង្គរសម្រាប់អ្នកសិក្សាស្រាវជ្រាវ | FOC02 | ឥតបង់ថ្លៃ | ៧ថ្ងៃ | |
| ២៧ | ការចូលក្នុងឧទ្យានអង្គរសម្រាប់អ្នកឆ្លងកាត់ | FOC03 | ឥតបង់ថ្លៃ | ៥ថ្ងៃ | |
| ៣.២ | **ការស្នើសុំសាងសង់ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ក្រោមសមត្ថកិច្ចរបស់អាជ្ញាធរអប្សរា** | | | | |
| ២៨ | ការស្នើសុំសង់លំនៅដ្ឋានប្រជាពលរដ្ឋ | FOC04 | ឥតបង់ថ្លៃ | ៣០ថ្ងៃ | ១ឆ្នាំ |
| ២៩ | ការស្នើសុំសង់អគារ និងហេដ្ឋារចនាសម្ព័ន្ធវិស័យឯកជន | FOC05 | ឥតបង់ថ្លៃ | ៣០ថ្ងៃ | ១ឆ្នាំ |
| ៣០ | ការស្នើសុំសង់អគារ និងហេដ្ឋារចនាសម្ព័ន្ធបំរើសេវាសាធារណៈ | FOC06 | ឥតបង់ថ្លៃ | ៣០ថ្ងៃ | ១ឆ្នាំ |
| ៣១ | ការស្នើសុំសង់សំណង់អគារ និងហេដ្ឋារចនាសម្ព័ន្ធសាសនា | FOC07 | ឥតបង់ថ្លៃ | ៣០ថ្ងៃ | ១ឆ្នាំ |
| ៣២ | ការស្នើសុំសង់ទ្រុងជ្រូក មាន់ ទា.....មានលក្ខណៈស្រាល | FOC08 | ឥតបង់ថ្លៃ | ភ្លាមៗនៅទីតាំងជាក់ស្តែង ដោយក្រុមការងារសេហគមន៍ | |

APSARA

| | | | | | |
|---|---|---|---|---|---|
| ៣.៣ ការស្នើសុំការអនុញ្ញាតផ្សេងៗ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ក្រោមសមត្ថកិច្ចរបស់អាជ្ញាធរអប្សរា | | | | | |
| ៣៣ | ការសុំរៀបចំពិធីបុណ្យនានាតាមជំនឿប្រពៃណីខ្មែររបស់សហគមន៍ មិនមែនអាជីវកម្ម | FOC10 | ឥតបង់ថ្លៃ | ៥ថ្ងៃ | |
| ៣៤ | ការស្នើសុំឯកសារ និងផែនទីផ្លូវការមួយចំនួន ស្តីពីការកំណត់តំបន់ការពាររមណីយដ្ឋានអង្គរ និងតំបន់ពាក់ព័ន្ធ | FOC11 | ឥតបង់ថ្លៃ | ៥ថ្ងៃ | |
| ៣៥ | ការស្នើសុំអ្នកជំនាញជួយធ្វើបទបង្ហាញដល់និសិត្ស កម្មសិក្សាការី និងគណៈប្រតិភូ ស្តីពីការស្វែងយល់ពីការគ្រប់គ្រងរមណីយដ្ឋានអង្គរ | FOC12 | ឥតបង់ថ្លៃ | ៥ថ្ងៃ | |

សៀមរាប ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៧

អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា

**អគ្គនាយក**

**ស៊ុំ ម៉ាប់**

# លក្ខខណ្ឌចាំបាច់សម្រាប់អ្នកប្រើប្រាស់សេវា (I)

១.មិនអនុញ្ញាតឱ្យរៀបចំពិធីសម្តែងសិល្បៈ ដូចជា៖ ការប្រគុំតន្ត្រីបែបកន្ត្រាក់អារម្មណ៍ ដែលមិនបានលើកតម្លៃសិល្បៈខ្មែរ និងអាចទទួលរងនូវការរិះគន់ពីមិតិសាធារណជន។

២.មិនអនុញ្ញាតឱ្យរៀបចំពិធី ចំថ្ងៃបុណ្យមាឃបូជា ពិសាខបូជា ភ្ជុំបិណ្ឌ និងថ្ងៃកាន់ទុក្ខជាតិ។

៣.ការរៀបចំពិធីទទួលទានអាហារពេលល្ងាចឬសម្តែងសិល្បៈ ចំថ្ងៃបុណ្យជាតិ ដែលមានចែងក្នុងប្រតិទិនឈប់សម្រាកប្រចាំឆ្នាំ ត្រូវបង់ថ្លៃសេវាបន្ថែមចំនួន៣០ភាគរយ នៃតម្លៃសរុប។

៤.ការស្នើសុំរៀបចំពិធី ត្រូវចំថ្ងៃបុណ្យអន្តរជាតិ៖ ថ្ងៃបុណ្យណូអែល ថ្ងៃចូលឆ្នាំសាកល និងថ្ងៃ១៤កុម្ភៈ ត្រូវបង់ថ្លៃសេវាបន្ថែម១០០ភាគរយនៃតម្លៃសរុប។

៥.ការរៀបចំពិធីទទួលទានអាហារពេលព្រឹក អនុញ្ញាតជូនចាប់ពីម៉ោង០៥:០០ ដល់ម៉ោង០៧:៣០។ ប្រសិនបើលើសពីម៉ោង០៧:៣០ នឹងត្រូវរងការបង់ពិន័យ៥០ភាគរយ នៃចំនួនភ្ញៀវសរុប ហើយត្រូវបញ្ឈប់ពិធីជាបន្ទាន់។

៦.ការរៀបចំពិធីទទួលទានអាហារពេលល្ងាចឬសម្តែងសិល្បៈ អនុញ្ញាតជូនចាប់ពីម៉ោង១៨:០០រហូតដល់ម៉ោង២២:៣០។ ប្រសិនបើលើសពីម៉ោង២២:៣០ នឹងត្រូវរងការបង់ពិន័យ៥០ភាគរយ នៃចំនួនភ្ញៀវសរុប ហើយត្រូវបញ្ឈប់ពិធីជាបន្ទាន់។

៧.ការរៀបចំពិធីCocktail អនុញ្ញាតជូនចាប់ពីម៉ោង១៧:០០ ដល់ម៉ោង១៩:០០។ ប្រសិនបើលើសពីម៉ោង១៩:០០នឹងត្រូវរងការបង់ពិន័យ៥០ភាគរយនៃតម្លៃសរុប ហើយត្រូវបញ្ឈប់ពិធីជាបន្ទាន់។

៨.ក្រោយពីបានការអនុញ្ញាតរៀបចំពិធី ករណីក្រុមហ៊ុនចង់បន្ថែមចំនួនភ្ញៀវ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ៣ថ្ងៃ (នៃថ្ងៃធ្វើការ) មុនថ្ងៃរៀបចំពិធី។ ការជូនដំណឹងតិចជាង៣ថ្ងៃ ត្រូវបង់បន្ថែម៥០ភាគរយនៃចំនួនភ្ញៀវលើស។ ករណីក្រុមហ៊ុនមិនបានជូនដំណឹងអំពីចំនួនភ្ញៀវលើស ត្រូវបង់ពិន័យបន្ថែមទ្វេដងតាមថ្លៃគោលការណ៍បានកំណត់សម្រាប់ចំនួនភ្ញៀវលើស។

៩. ក្រោយពីដាក់ពាក្យស្នើសុំ ឬបានការអនុញ្ញាតរៀបចំពិធីរួច បើក្រុមហ៊ុនមានបំណងផ្លាស់ប្តូរទីតាំងឬកាលបរិច្ឆេទ ត្រូវជូនដំណឹង៣ថ្ងៃ(នៃថ្ងៃធ្វើការ) មុនថ្ងៃរៀបចំពិធី។ ការជូនដំណឹងតិចជាង៣ថ្ងៃ(នៃថ្ងៃធ្វើការ) ត្រូវបង់បន្ថែម២០ភាគរយនៃតម្លៃសរុប។

១០. ការថតរូបភាពសន្លឹក-វីដេអូ ចងក្រងទុកជាអនុស្សាវរីយ៍នៅក្នុងពិធី ត្រូវស្នើសុំការអនុញ្ញាតពីអាជ្ញាធរអប្សរាជាមុន។ រូបភាពថតនៅក្នុងពិធីនេះ មិនអាចធ្វើជាកម្មវត្ថុនៃការផ្សព្វផ្សាយផលិតផល ឬពាណិជ្ជកម្មឡើយ។

១១. ក្រុមហ៊ុនដែលទទួលបានការអនុញ្ញាតរៀបចំពិធី ត្រូវគោរពតាមកិច្ចសន្យាឱ្យបានត្រឹមត្រូវ។ ករណីក្រុមហ៊ុនមិនគោរពតាមលក្ខខណ្ឌកំណត់ក្នុងកិច្ចសន្យា អាជ្ញាធរអប្សរាអាចពិន័យ ឬមិនអនុញ្ញាតឱ្យរៀបចំពិធីនៅលើកក្រោយទៀត។

១២. ក្រុមហ៊ុនស្នើសុំ ត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះការខូចខាតទាំងឡាយណា ដែលបង្កឡើងដោយភ្ញៀវចូលក្នុងពិធី។

១៣. ក្រុមហ៊ុនស្នើសុំ ត្រូវចូលរួមផ្សព្វផ្សាយក្រមប្រតិបត្តិអង្គរជូនភ្ញៀវចូលរួមពិធី។

១៤. ក្នុងករណីចាំបាច់និងបន្ទាន់ អាជ្ញាធរអប្សរាសូមរក្សាសិទ្ធិ ផ្លាស់ប្តូរទីតាំងប្រាសាទដែលបានស្នើសុំរៀបចំពិធី។

១៥. ការស្នើសុំរៀបចំពិធី នៅទីតាំងផ្សេងដែលពុំមានចែងក្នុងតារាង អាជ្ញាធរអប្សរានឹងពិនិត្យលើកម្មវត្ថុស្នើសុំតាមករណីជាក់ស្តែង។

១៦. ក្រោយពីក្រុមហ៊ុនបានបង់ថ្លៃសេវារួចរាល់ ក្រុមហ៊ុនពុំអាចស្នើសុំដកថវិកាពីអាជ្ញាធរអប្សរាបានឡើយ ទោះបីជាចំនួនភ្ញៀវមានការថយចុះក៏ដោយ លើកលែងតែការស្នើសុំលុបពិធីដូចមានលក្ខខណ្ឌកំណត់ក្នុងកិច្ចសន្យា។

## កំណត់សម្គាល់ សេវា (II)

១.ការថតខ្សែភាពយន្ត គឺសំដៅដល់ការផលិតភាពយន្តឬវីដេអូ ក្នុងគោលបំណងជាក់លាក់ណាមួយ សម្រាប់ការបញ្ចាំងតាមរោងភាពយន្ត ការលក់ជាឌីវីឌី(DVD) ការលក់តាមប្រព័ន្ធ Internet ឬការលក់តាមប្រព័ន្ធបច្ចេកវិទ្យាទំនើបដែលអាចនឹងកើតឡើងក្នុងអនាគតកាល និងការលក់ចែកចាយទូទាំងពិភពលោកតាមមធ្យោបាយផ្សេងទៀត ដោយមានច្បាប់អនុញ្ញាតថតជាផ្លូវការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

- ការថតខ្សែភាពយន្ត **"ខ្នាតធំ"** ជាទូទៅមានសមាជិកក្រុមការងារបច្ចេកទេសថតច្រើនជាង២០នាក់ មានតួសម្តែងសំខាន់ៗនិងអ្នកសម្តែងបន្ទាប់បន្សំចាប់ពី៥០នាក់ឡើងទៅ មានម៉ាស៊ីនថត (Camera)ចាប់ពី០៣គ្រឿងឡើងទៅ និងមានសម្ភារបច្ចេកទេសជាច្រើនទៀត។
- ការថតខ្សែភាពយន្ត **"ខ្នាតតូច"** ជាទូទៅមានសមាជិកក្រុមការងារបច្ចេកទេសថតតិចជាង២០នាក់ មានតួសម្តែងនិងអ្នកសម្តែងបន្ទាប់បន្សំតិចជាង៥០នាក់ មានម៉ាស៊ីនថត(Camera)តិចជាង០៣គ្រឿង និងមានសម្ភារបច្ចេកទេសមួយចំនួនតូច។

២.ការថតរូបភាព-វីដេអូ **"បរទេស"** សំដៅទៅលើការថតទាំងឡាយណា ដែលមានប្រភពធនធានចំណាយមកពីបរទេស និងមាន**ផលិតករឬអ្នកដឹកនាំ**មានសញ្ជាតិបរទេស។

៣.ការថតរូបភាព-វីដេអូ **"ក្នុងស្រុក"**សំដៅទៅលើការថតទាំងឡាយណា ដែលមានប្រភពធនធានចំណាយក្នុងប្រទេសកម្ពុជាឬមកពីបរទេស និងមាន**ផលិតករឬអ្នកដឹកនាំ**មានសញ្ជាតិជាខ្មែរ។

៤.ការថត**ស្ប៉តពាណិជ្ជកម្ម** ឬការថត**កម្មវិធីទូរទស្សន៍** សំដៅដល់ការថតរូបភាពឬវីដេអូ ក្នុងគោលបំណងផ្សព្វផ្សាយ ឬលក់ផលិតផលឬសេវា តាមទូរទស្សន៍ តាមប្រព័ន្ធ Internet តាមប្រព័ន្ធបច្ចេកវិទ្យាទំនើប ដែលអាចនឹងកើតឡើងក្នុងពេលអនាគតជាដើម។

## លក្ខខណ្ឌចាំបាច់សម្រាប់អ្នកប្រើប្រាស់សេវា (II)

១.រាល់ការដាក់ពាក្យស្នើសុំថត ក្រុមហ៊ុន ផលិតកម្ម ឬឯកត្តបុគ្គលត្រូវភ្ជាប់ជាមួយបញ្ជីសម្ភារថត ហើយសម្ភារថតនោះ មិនអាចយកទៅប្រើប្រាស់ក្នុងគោលបំណងថតផ្សេងទៀត ក្រៅពីកម្មវត្ថុដែលស្នើសុំនោះបានឡើយ។

២.ប្រសិនបើ ភាគីស្នើសុំថតមានបំណងឱ្យរថយន្តដឹកសម្ភារថតវីដេអូ ចូលក្នុងតំបន់ហាមឃាត់នៃប្រាសាទ ភាគីស្នើសុំត្រូវតែបញ្ជាក់ក្នុងលិខិតស្នើសុំ ឬជូនដំណឹងជាលាយល័ក្ខអក្សរឱ្យបានមុនយ៉ាងតិច៥ថ្ងៃ (នៃថ្ងៃធ្វើការ) ដោយមានភ្ជាប់នូវតារាងសម្ភារថតវីដេអូឱ្យបានលម្អិត ដើម្បីឱ្យអាជ្ញាធរអប្សរាពិនិត្យ និងសម្រេចអនុញ្ញាត ឬមិនអនុញ្ញាត។

៣.ក្រុមហ៊ុន ផលិតកម្ម ឬឯកត្តបុគ្គលដែលទទួលបានការអនុញ្ញាតថត មានសិទ្ធិពេញលេញក្នុងការប្រើប្រាស់រូបភាពឬវីដេអូ តបតាមកម្មវត្ថុស្នើសុំ តែរូបភាពទាំងនោះមិនត្រូវបានអនុញ្ញាតឱ្យយកទៅប្រើប្រាស់ សម្រាប់គម្រោងឬគោលបំណងផ្សេងទៀត ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរអប្សរាជាដាច់ខាត។ ក្នុងករណី ក្រុមហ៊ុន ផលិតកម្ម ឬឯកត្តបុគ្គលមានគោលបំណងប្រើប្រាស់រូបភាពដែលបានថតហើយសម្រាប់គម្រោងថ្មីទៀត ក្រុមហ៊ុន ផលិតកម្ម ឬឯកត្តបុគ្គលត្រូវមានកាតព្វកិច្ចដាក់ពាក្យស្នើសុំសិទ្ធិប្រើប្រាស់រូបភាពជាថ្មី ពីអាជ្ញាធរអប្សរា។

៤.អ្នកស្នើសុំថតរូបភាពសន្លឹក និងថតវីដេអូ ត្រូវធានាផ្តល់រូបភាពសន្លឹក និងវីដេអូចំនួន១ច្បាប់ក្រោយពេលថតចប់ជូនអាជ្ញាធរអប្សរាពិនិត្យ ដូចមានចែងក្នុងកិច្ចសន្យាថត។

៥.ករណីការដាក់ពាក្យស្នើសុំ ហួសរយៈពេលនៃថ្ងៃទទួលពាក្យ ភាគីស្នើសុំថតត្រូវបង់ថ្លៃសេវាចំនួន**២០ភាគរយ**បន្ថែមពីលើថ្លៃសេវា ដែលបានកំណត់ប្រចាំថ្ងៃ។

៦.ការដាក់ពាក្យស្នើសុំថត ត្រូវចំនឹងថ្ងៃបុណ្យជាតិឬអន្តរជាតិ ដែលមានចែងក្នុងប្រតិទិនឈប់សម្រាកប្រចាំឆ្នាំរបស់ប្រទេសកម្ពុជា ភាគីអ្នកស្នើសុំថតត្រូវបង់ថ្លៃសេវាបន្ថែម **ចំនួន៣០ភាគរយ** នៃ **"ថ្លៃសេវា"** ប្រចាំថ្ងៃ។

# លក្ខខណ្ឌចាំបាច់សម្រាប់អ្នកប្រើប្រាស់សេវា (II)

៧.ក្រោយពីការដាក់ពាក្យស្នើសុំរួច ឬទទួលបានការអនុញ្ញាតថតរូបភាព-វីដេអូ បើភាគីស្នើសុំថតមានបំណងផ្លាស់ប្តូរកាលបរិច្ឆេទថត ភាគីស្នើសុំត្រូវធ្វើជូនដំណឹងជាលាយលក្ខណ៍អក្សរ មុន៣ថ្ងៃ(នៃថ្ងៃធ្វើការ)។ ការជូនដំណឹងតិចជាង៣ថ្ងៃ ត្រូវបង់បន្ថែម២០ភាគរយ។

៨.ប្រសិនបើ ការស្នើសុំថតមានរយៈពេល១សប្តាហ៍ អាជ្ញាធរអប្សរាបញ្ចុះតម្លៃជូនចំនួន**០២ថ្ងៃ** ដោយគិតថ្លៃថតត្រឹមតែចំនួន០៥ថ្ងៃប៉ុណ្ណោះ។ ក្នុងករណី មានការស្នើសុំតុបតែងទីតាំងថត អាជ្ញាធរអប្សរានឹងបញ្ចុះតម្លៃ**ចំនួន៥០%** សម្រាប់ថ្ងៃរៀបចំតុបតែងទីតាំងថត និងថ្ងៃរុះរើការតុបតែងទីតាំងថតចេញ ដែលមិនប៉ះចំថ្ងៃថត។

៩.ភាគីអ្នកស្នើសុំថត មានសិទ្ធិតែថតប៉ុណ្ណោះ និងមិនមានសិទ្ធិរុះរើហេដ្ឋារចនាសម្ព័ន្ធ ដែលមាននៅទីតាំងថតឡើយ។

១០.ការបង់ថ្លៃសេវាថតជូនអាជ្ញាធរអប្សរា មិនរាប់បញ្ចូលថ្លៃទិញសំបុត្រចូលរមណីយដ្ឋានអង្គរសម្រាប់ក្រុមការងារថតដែលជាជនបរទេសនោះទេ។

១១.ក្រុមការងារថត ត្រូវគោរពតាមម៉ោងបិទ-បើកប្រាសាទ និងគោរពក្រមប្រតិបត្តិអង្គរឱ្យបានត្រឹមត្រូវ។ ក្នុងករណី មានការស្នើសុំថតនៅលើទីតាំងហាមឃាត់ ឬចំម៉ោងបិទការទស្សនាក្នុងតំបន់ប្រាសាទ អាជ្ញាធរអប្សរានឹងពិនិត្យលើកម្មវត្ថុស្នើសុំជាក់ស្តែង។

១២.ការថតរូបភាពសន្លឹក (Photography) សម្រាប់ផ្សព្វផ្សាយពីផលិតផលជាតិ ឬផលិតផលបរទេស ក្នុងគោលបំណងធ្វើអាជីវកម្មតាមគ្រប់រូបភាព ភាគីស្នើសុំថតត្រូវចុះកិច្ចសន្យាប្រើប្រាស់រូបភាពដោយឡែក ដោយមានបញ្ជាក់ពីរយៈពេលធ្វើអាជីវកម្មជាក់លាក់ណាមួយ។ ក្នុងករណីកិច្ចសន្យាផុតកំណត់ ភាគីស្នើសុំថតត្រូវធ្វើការសុំសិទ្ធិក្នុងការប្រើប្រាស់រូបភាពជាថ្មីម្តងទៀត និងបង់ប្រាក់តាមតារាងថ្លៃសេវាដែលបានកំណត់។

១៣.ភាគីស្នើសុំថតទាំងអស់ ត្រូវបង់ថ្លៃសេវា តាមការកំណត់ក្នុងតារាងតម្លៃដែលបានកំណត់ដោយអាជ្ញាធរអប្សរា លើកលែងតែមានការអនុគ្រោះថ្លៃសេវាពីអាជ្ញាធរអប្សរា។

១៤.ភាគីអ្នកស្នើសុំថតត្រូវបង់ថ្លៃសេវា តាមការកំណត់ក្នុងកិច្ចសន្យា ដែលមានចុះហត្ថលេខាពីអគ្គនាយកអាជ្ញាធរអប្សរា។

១៥.ក្រៅពីថ្លៃសេវាដែលមានចែងនៅក្នុងកិច្ចសន្យាដែលត្រូវបង់តាមរយៈបេឡាករ ឬគណនេយ្យនៃអាជ្ញាធរអប្សរានៅធនាគារជាតិ ភាគីស្នើសុំពុំមានការបង់ថ្លៃសេវាណាមួយផ្សេងទៀតឡើយ។